ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន
លេខៈ....០៩ / សរណ...សក.ដជ

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ៧ ឆ្នាំ ២០០៤

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តន៍កាតព្វកិច្ចធានារ៉ាប់រងភារៈកិច្ចទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ

ដើម្បីធានាអោយកិច្ចដំណើរការអនុវត្តន៍ប្រកាសអន្តរក្រសួងលេខ៦៥៣ប្រក.សហវ.សក.ទច.មជ ចុះថ្ងៃទី ១៦ ខែតុលាឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង ប្រកាសអន្តរក្រសួងលេខ ៦៥៤ ប្រក.សហវ.សក.ទច.មជ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ប្រព្រឹត្តទៅអោយបានល្អប្រសើរ មានតម្លាភាព និង ធានាអភិបាលកិច្ចល្អ ក្រសួងសាធារណការ និង ដឹកជញ្ជូនសូមធ្វើការណែនាំដល់អគ្គនាយកដ្ឋានដឹកជញ្ជូន និង មន្ទីរសាធារណការ និង ដឹកជញ្ជូនគ្រប់ខេត្ត - ក្រុង ទាំងអស់អនុវត្តដូចតទៅ ÷

### I- ប្រភេទមធ្យោបាយដឹកជញ្ជូន

ក- យានយន្តជាប់កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន

ប្រភេទយានយន្តដែលត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន សំរាប់គ្រោះថ្នាក់ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមាន ÷

- យានយន្តធ្វើអាជីវកម្មដឹកទំនិញ - ដឹកអ្នកដំណើរ និង ភ្ញៀវទេសចរ .
- យានយន្តគ្រប់ប្រភេទ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន - រោងចក្រ - សហគ្រាស
- យានយន្តរបស់អង្គការក្រៅរដ្ឋាភិបាល - អង្គការអន្តរជាតិ និង សមាគមនានា
- ឧបករណ៍លាយស៊ីម៉ង់តិ៍ ដែលធ្វើចលនាផ្លាស់ប្តូរទីកន្លែងដោយម៉ាស៊ីនផ្ទាល់ ឬ អូសដោយក្បាលសណ្តោង
- ត្រីចក្រយានយន្ត ដែលប្រើប្រាស់សំរាប់ធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ និង អ្នកដំណើរ ។

ខ- រថយន្តជាប់កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ

ប្រភេទយានយន្តដែលត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរសំរាប់គ្រោះថ្នាក់ ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមាន ÷

- រថយន្តដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ
- រថយន្តដឹកភ្ញៀវទេសចរ
- រថយន្តដឹកសិស្ស
- រថយន្តដឹកកម្មករ- កម្មការិនីរបស់ក្រុមហ៊ុន - រោងចក្រ ឬ សហគ្រាស
- ត្រីចក្រយានយន្តដឹកជញ្ជូនអ្នកដំណើរ

## II- សំណុំឯកសារដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម

រាល់សំណុំឯកសារដែលត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនមានដូចខាងក្រោម ÷

| | |
|---|---|
| ១- ពាក្យសុំមានបិទតែមប្រយ៉ត្រឹមត្រូវ | ០១ ច្បាប់ |
| ២- ប័ណ្ណសំគាល់យានយន្តថតចំលង | ០១ ច្បាប់ |
| ៣- វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តច្បាប់ដើម | ០១ ច្បាប់ |
| ៤- ប័ណ្ណបើកបរថតចំលង | ០១ ច្បាប់ |
| ៥- ប័ណ្ណសន្យារ៉ាប់រងថតចំលង | ០១ ច្បាប់ |
| ៦- បង្កាន់ដៃបង់សិទ្ធិ | ០១ ច្បាប់ |

## III- លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន

១- ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនចំពោះយានយន្តដឹកជញ្ជូនទំនិញគ្រប់ប្រភេទ ដែលបានទិញធានារ៉ាប់រងទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង ធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ចំពោះរថយន្តដឹកអ្នកដំណើរ - ភ្ញៀវទេសចរ - សិស្ស - បុគ្គលិក - កម្មករ - កម្មការិនី ។ល។

២- ក្នុងករណីដែលម្ចាស់យានយន្ត ឬ អ្នកបើកបរមិនបានទិញធានារ៉ាប់រង ដូចបានបញ្ជាក់ខាងលើនេះទេ ក្រសួងសាធារណការ និង ដឹកជញ្ជូន អាចចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនអោយប្រើប្រាស់ជាបណ្តោះអាសន្ន ។ ក្រោយរយៈពេល៦០ថ្ងៃនៃការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មរួចមក ម្ចាស់យានយន្ត ឬ អ្នកបើកបរនៅតែមិនព្រមបំពេញកាតព្វកិច្ចធានារ៉ាប់រង ក្រសួងសាធារណការ និង ដឹកជញ្ជូនត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម និង វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ឬ បញ្ឈប់មិនអោយយានយន្តទាំងនោះធ្វើចរាចរនៅលើផ្លូវសាធារណៈតទៅទៀតឡើយ ។ ឯកសារដកហូតនេះនឹងត្រូវប្រគល់ទៅអោយម្ចាស់យានយន្ត ឬ អ្នកបើកបរវិញ

នៅពេលដែលខ្លួនបានបង្ហាញដល់មន្ត្រីជំនាញមន្ត្រីនៃក្រសួសាធារណការ និង ដឹកជញ្ជូននូវកាតព្វកិច្ចធានារ៉ាប់រង ដែលខ្លួនបានទិញពីក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកណាមួយ ។

## IV- គ្រប់ទំណន្ទៃនៃកាតព្វកិច្ចធានារ៉ាប់រង

ក្រុមហ៊ុនធានារ៉ាប់រង មិនទទួលខុសត្រូវចេញសំណងអោយអ្នកដែលត្រូវបានធានារ៉ាប់រងភារៈទទួលខុសត្រូវ យានយន្ត ឬ ធានារ៉ាប់រងតតិយជន និង ធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរក្នុងករណី :

-អ្នកបើកបរគ្មានប័ណ្ណបើកបរស្របច្បាប់ ឬ ប័ណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយានយន្ត ឬ ប័ណ្ណបើកបរហួសសុពលភាព

-អ្នកបើកបរស្ថិតនៅក្នុងភាពស្រវឹងជាក់ស្តែង ហើយមានអត្រាជាតិអាល់កុលចាប់ពី ០,៨០ ក្រាមក្នុងឈាមមួយលីត្រឡើងទៅ ឬ ស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងញៀន ផ្អែកតាមការធ្វើកោសល្យវិច្ឆ័យរបស់មន្ទីរពេទ្យ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុភ្នាក់ងារត្រួតពិនិត្យរបស់ក្រុមហ៊ុនធានារ៉ាប់រង ឬ នគរបាលចរាចរខេត្ត - ក្រុង

-ការខូចខាតដែលកើតឡើងចំពោះអ្នកដំណើរនៅក្នុងយានយន្ត ដែលជាប់កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ហើយម្ចាស់យានយន្ត ឬ អ្នកបើកបរគ្មានការធានារ៉ាប់រង

-នាយកដ្ឋានឧស្សាហកម្ម និង ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានបញ្ជាក់ថា ប័ណ្ណធានារ៉ាប់រងនោះមិនត្រឹមត្រូវ

## V- ការសហការអនុវត្តកាតព្វកិច្ចធានារ៉ាប់រង

មន្ទីរសាធារណការ និង ដឹកជញ្ជូន និង ប៉ូលីសចរាចរគ្រប់ខេត្ត-ក្រុង ត្រូវរួមសហការអនុវត្តការត្រួតពិនិត្យ និងឆែកឆេរនូវរាល់ឯកសារដឹកជញ្ជូនដូចជាប័ណ្ណសំគាល់យានយន្ត ប័ណ្ណបើកបរ វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និង ប័ណ្ណសន្យារ៉ាប់រងចំពោះយានយន្តដឹកទំនិញ និង អ្នកដំណើរគ្រប់ប្រភេទនៅតាមចំណតរថយន្តខេត្ត - ក្រុងអោយបានម៉ឺងម៉ាត់ជាប់ជាប្រចាំ ។

ក្នុងករណីយានយន្តមិនមានឯកសារដឹកជញ្ជូនគ្រប់គ្រាន់ និង មិនមានលតាប័ត្រធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង លតាប័ត្រធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរដែលមានបិទនៅលើកញ្ចក់មុខផ្នែកខាងក្នុង មិនត្រូវអនុញ្ញាតអោយចូលចតនៅចំណតរថយន្តឡើយ ។

នគរបាលចរាចរគ្រប់ខេត្ត-ក្រុងត្រូវ ÷

១-ជាកពិន័យ និង ណែនាំដល់ម្ចាស់យានយន្ត និង ប្រតិបត្តិករដឹកជញ្ជូនអោយទៅទិញធានារ៉ាប់រងក្នុងរយៈពេលយ៉ាងយូរ៧ ថ្ងៃ ។

២-ក្នុងករណីមិនបានអនុវត្តតាមការណែនាំខាងលើ ត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និង វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ។

៣-ក្នុងករណីមិនរាងចាល ត្រូវឃាត់យានយន្តទុកជាបណ្តោះអាសន្នមិនអោយដំណើរការដឹកជញ្ជូនបន្តទៀត រហូតដល់ម្ចាស់យានយន្ត ឬ ប្រតិបត្តិករដឹកជញ្ជូន បានផ្តល់ឯកសារកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង ឯកសារកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរត្រឹមត្រូវតាមកាលកំណត់ ។

អគ្គនាយកដ្ឋានដឹកជញ្ជូន និង មន្ទីរសាធារណការ និង ដឹកជញ្ជូនគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តតាមខ្លឹមសារសារាចរណែនាំនេះ និង ធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយដល់គ្រប់ក្រុមហ៊ុនដឹកជញ្ជូន ម្ចាស់យានយន្ត និង ប្រតិបត្តិករដឹកជញ្ជូន អោយបានយល់ជ្រួតជ្រាបអំពីយន្តការនៃការអនុវត្តន៍សារាចរណែនាំក្នុងស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធិភាពខ្ពស់ ។

រដ្ឋមន្ត្រី

ស៊ុន ចាន់ថុល

<u>កន្លែងទទួល</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងទេសចរ
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋានដឹកជញ្ជូន
-គ្រប់មន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្ត-ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ- កាលប្បវត្តិ